ADVANCING EDUCATION SAFELY SY 2020-2021

# ត្រឡប់មកវៀននៅសាលាវិញ ដោយផ្ទាល់...*ដោយសុវត្ថិភាព*



ក្រសួងអប់រំនឹងចាប់ផ្តើមផ្តល់ជូនក្រុមគ្រួសារនូវជម្រើសក្នុងការផ្លាស់ប្តូរទៅជាការសិក្សាបញ្ចូលគ្នានៃ ការទៅរៀននៅសាលាដោយផ្ទាល់ និង ការសិក្សាតាមកុំព្យូទ័រ (ការសិក្សាបញ្ចូលគ្នា (hybrid learning)) សម្រាប់សិស្សានុសិស្ស ក៏ប៉ុន្តែយើងអាចធ្វើដូច្នោះទៅបាន ដរាបណាកិច្ចខិតខំប្រឹងប្រែងរបស់ ក្រសួងសុខាភិបាលនៃទីក្រុងហ្វីឡាដែលហ្វ្យា និង សាលារបស់យើង អាចជួយធ្វើឱ្យមានសុវត្ថិភាព។

ជម្រើសនៃការសិក្សានេះនឹងផ្តល់ជូនក្រុមគ្រួសារ ដោយសន្សឹមៗ និង ជាដំណាក់កាលៗ ចាប់ផ្តើមពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ២ ។ ដំណាក់កាលនេះអនុញ្ញាតឱ្យយើងតាមដានការប្រតិបត្តិផ្នែក សុខភាព និង សុវត្ថិភាព នៅតាមសាលារៀន និង ធានាថាលក្ខខណ្ឌជំនួយនៃ ខូវីដ-១៩ នឹងនៅតែបន្តសម្រាប់ការមករៀននៅសាលាដោយផ្ទាល់។ នៅពេលយើងរៀបផែនការសម្រាប់ការមករៀននៅសាលាដោយផ្ទាល់ មានកត្តាជាច្រើនដែលជះឥទ្ធិពលលើ វិធី ពេលវេលា និង បើសិនជាយើងអាចឈានទៅមុខជាមួយការមករៀននៅសាលាដោយផ្ទាល់នេះ។ សេចក្តីណែនាំដ៏សង្ខេបនេះ ផ្តល់ជូននូវព័ត៌មានដើម្បីជួយឱ្យលោកអ្នកធ្វើការជ្រើសរើសត្រឹមត្រូវសម្រាប់ក្រុមគ្រួសាររបស់លោកអ្នក។ សូមពិចារណាលើព័ត៌មាននេះដោយយកចិត្តទុកដាក់នៅពេលលោកអ្នកធ្វើការជ្រើសរើស។

## តើគេឱ្យសិស្សានុសិស្សចាប់ផ្តើម នៅពេលណា និង តាមវិធីណា?

យើងចាប់ផ្តើមជាមួយសិស្សក្មេងជាងគេរបស់យើង ពីព្រោះការស្រាវជ្រាវបានបង្ហាញថាពួកគេទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីការរៀនសូត្រនៅសាលាដោយផ្ទាល់។ បន្ទាប់ពីនោះ ក្រុមផ្សេងៗទៀតនឹងចាប់ផ្តើមសន្សឹមៗ ដរាបណាមានសុវត្ថិភាពក្នុងការធ្វើបែបនេះ។

| ដំណាក់កាល | ក្រុមសិស្ស | ពេលវេលានៃការត្រឡប់មកសាលា |
|---|---|---|
| ១ | សិស្សានុសិស្សថ្នាក់ មត្តេយ្យ ដល់ថ្នាក់ទី ២ ទាំងអស់ | សប្តាហ៍នៃថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២០<br>*ផ្អែកលើកាលវិភាគរបស់កូនលោកអ្នក* |
| ២ | សិស្សានុសិស្សដែលមានតម្រូវការស្មុគស្មាញ* ថ្នាក់ទី ៣ ដល់ទី ១២<br>**សិស្សដែលមានពិការភាពរាងកាយ មានបញ្ហាវិញ្ញាញ មានស្ថានភាពសុខភាពធ្ងន់ធ្ងរផ្សេងទៀត និង មានបញ្ហាលំបាកជាច្រើនក្នុងការរៀនសូត្រ* | នឹងធ្វើការសម្រេច<br>ផ្អែកលើស្ថានភាព<br>*គោលដៅ៖ ខែមករា* |
| ៣ | សិស្សថ្នាក់ទី ៩ និង សិស្ស CTE (អាជីព និង បច្ចេកទេស) | នឹងធ្វើការសម្រេច<br>ផ្អែកលើស្ថានភាព |
| ៤+ | បទបញ្ញា និង ពេលវេលា សម្រាប់ក្រុមសិស្សានុសិស្សដែលនៅសល់ នឹងធ្វើការសម្រេច ដោយផ្អែកលើស្ថានភាព | |

### ផែនការបច្ចុប្បន្ននេះ តើកាលវិភាគរបស់កូនខ្ញុំនឹងទៅជាយ៉ាងណាដែរ បើសិនជាខ្ញុំជ្រើសរើស កម្មវិធីសិក្សាបញ្ចូលគ្នា ឬ សិក្សាតាមកុំព្យូទ័រ?

សិស្សានុសិស្សទាំងអស់នឹងទទួលការបង្ហាត់បង្រៀនរយៈពេលប្រាំថ្ងៃ ការបង្ហាត់បង្រៀនដោយផ្ទាល់ពីគ្រូរបស់ពួកគេ និង ការសិក្សាតាមកុំព្យូទ័រ ១០០% នៅថ្ងៃពុធ។ ការរៀបចំកាលវិភាគនេះ ដាក់កម្រិតចំនួនសិស្សានុសិស្សនៅសាលាជារៀងរាល់ថ្ងៃ និង ជួយដល់សុវត្ថិភាពនៃការឱ្យនៅឃ្លាតឆ្ងាយពីគ្នា។

<table>
<tr><th></th><th>ច័ន្ទ និង អង្គារ</th><th>ពុធ</th><th>ព្រហស្បត្តិ៍ និង សុក្រ</th></tr>
<tr><td>សិស្សក្រុម A</td><td>ការបង្ហាត់បង្រៀននៅសាលាដោយផ្ទាល់ (បង្ហាត់បង្រៀនផ្ទាល់) ជាមួយគ្រូ និង ការសិក្សាដោយឯករាជ្យ<br>ក្នុងអំឡុងពេលនៃការសិក្សាដោយឯករាជ្យ (រៀនខ្លួនឯង) គ្រូយកសិស្សចេញទៅបង្រៀនជាក្រុមតូចៗ</td><td rowspan="3">សិស្សានុសិស្សទាំងអស់រៀនពីផ្ទះ ហើយទទួលការបង្ហាត់បង្រៀនផ្ទាល់ កិច្ចការធ្វើដោយឯករាជ្យ និង ការបង្ហាត់បង្រៀនជាក្រុមតូចៗ។</td><td>ការបង្ហាត់បង្រៀននៅផ្ទះ (បង្ហាត់បង្រៀនផ្ទាល់) ជាមួយគ្រូ តាមរយៈការបង្រៀនផ្ទាល់តាមកុំព្យូទ័រ<br>ការសិក្សាដោយឯករាជ្យនៅផ្ទះ (រៀនខ្លួនឯង) និង កិច្ចការដែលគ្រូដាក់ឱ្យធ្វើ ស្របទៅនឹងការបង្ហាត់បង្រៀនផ្ទាល់</td></tr>
<tr><td>សិស្សក្រុម B</td><td>ការបង្ហាត់បង្រៀននៅផ្ទះ (បង្ហាត់បង្រៀនផ្ទាល់) ជាមួយគ្រូ តាមរយៈការបង្រៀនផ្ទាល់តាមកុំព្យូទ័រ<br>ការសិក្សាដោយឯករាជ្យនៅផ្ទះ (រៀនខ្លួនឯង) និង កិច្ចការដែលគ្រូដាក់ឱ្យធ្វើ ស្របទៅនឹងការបង្ហាត់បង្រៀនផ្ទាល់</td><td>ការបង្ហាត់បង្រៀននៅសាលាដោយផ្ទាល់ (បង្ហាត់បង្រៀនផ្ទាល់) ជាមួយគ្រូ និង ការសិក្សាដោយឯករាជ្យ<br>ក្នុងអំឡុងពេលនៃការសិក្សាដោយឯករាជ្យ (រៀនខ្លួនឯង) គ្រូយកសិស្សចេញទៅបង្រៀនជាក្រុមតូចៗ</td></tr>
<tr><td>សិស្សរៀនតាមកុំព្យូទ័រ ១០០%</td><td>ការបង្ហាត់បង្រៀននៅផ្ទះ (បង្ហាត់បង្រៀនផ្ទាល់) ជាមួយគ្រូ តាមរយៈការបង្រៀនផ្ទាល់តាមកុំព្យូទ័រ<br>ការសិក្សាដោយឯករាជ្យនៅផ្ទះ (រៀនខ្លួនឯង) និង កិច្ចការដែលគ្រូដាក់ឱ្យធ្វើ ស្របទៅនឹងការបង្ហាត់បង្រៀនផ្ទាល់</td><td>ការបង្ហាត់បង្រៀននៅផ្ទះ (បង្ហាត់បង្រៀនផ្ទាល់) ជាមួយគ្រូ តាមរយៈការបង្រៀនផ្ទាល់តាមកុំព្យូទ័រ<br>ការសិក្សាដោយឯករាជ្យនៅផ្ទះ (រៀនខ្លួនឯង) និង កិច្ចការដែលគ្រូដាក់ឱ្យធ្វើ ស្របទៅនឹងការបង្ហាត់បង្រៀនផ្ទាល់</td></tr>
<tr><td>គ្រូ</td><td>ផ្តល់ការបង្ហាត់បង្រៀនដោយផ្ទាល់ដល់ក្រុម A ផ្សាយការបង្ហរៀនផ្ទាល់ដល់ក្រុម B និង សិស្សានុសិស្សដែលរៀនតាមកុំព្យូទ័រ។ ក្នុងអំឡុងពេលសិក្សាដោយឯករាជ្យ ជួយសម្រួលក្នុងការបង្រៀនជាក្រុមតូចៗដល់ក្រុម A និង សិស្សដែលរៀនតាមកុំព្យូទ័រ ១០០%</td><td>ផ្តល់ការបង្ហាត់បង្រៀបពីចម្ងាយ និង ជួយសម្រួលក្នុងការបង្រៀនជាក្រុមតូចៗដល់សិស្សានុសិស្សទាំងអស់</td><td>ផ្តល់ការបង្ហាត់បង្រៀនដោយផ្ទាល់ដល់ក្រុម B ផ្សាយការបង្ហរៀនផ្ទាល់ដល់ក្រុម A និង សិស្សានុសិស្សដែលរៀនតាមកុំព្យូទ័រ។ ក្នុងអំឡុងពេលសិក្សាដោយឯករាជ្យ ជួយសម្រួលក្នុងការបង្រៀនជាក្រុមតូចៗដល់ក្រុម B និង សិស្សដែលរៀនតាមកុំព្យូទ័រ ១០០%</td></tr>
</table>

សាលាណាដែលមិនអាចអនុវត្តគំរូនេះបានដោយសារតែបញ្ហា ទំហំនៃអាគារ ត្រូវការបុគ្គលិក ឬ បញ្ហាប្រឈមផ្សេងៗទៀត នឹងអនុវត្តវិធីផ្សេងទៀតដែលអាចជួយដល់សុវត្ថិភាពរបស់សិស្សានុសិស្ស។

### តើ ផែនការ និង ពេលវេលា នៃការសិក្សាបញ្ចូលគ្នា ដែលគេបានស្នើឡើង អាចមានការផ្លាស់ប្តូរដែរឬទេ?

អាច។ ចំនួនគ្រូដែលប្រហែលជាមិនអាចបង្រៀននៅសាលាដោយផ្ទាល់ កម្រិតនៃការដាក់ចំនួនសិស្សនៅសាលាដោយសារការឱ្យនៅឃ្លាតឆ្ងាយពីគ្នា ចំនួនគ្រួសារដែលបានជ្រើសរើសបន្តការសិក្សាតាមកុំព្យូទ័រ១០០% ហើយផលប៉ះពាល់នៃស្ថានភាពផ្លាស់ប្តូរនៃជម្ងឺ ខូវីដ-១៩ គឺជាកត្តាទាំងអស់ ដែលនឹងជះឥទ្ធិពលលើ វិធី ពេលវេលា និង បើសិនជាយើងអាចផ្តល់ជូនការទៅរៀននៅសាលាដោយផ្ទាល់។ ក្រុមគ្រួសារគប្បីពិចារណាអំពីបញ្ហាទាំងនេះនៅពេលធ្វើការជ្រើសរើស។

### តើសិស្សានុសិស្សនឹងនៅជាមួយគ្រូបច្ចុប្បន្នរបស់ពួកគេដែរឬទេ?

គោលដៅរបស់យើងគឺចង់ឱ្យសិស្សានុសិស្សទាំងអស់នៅជាមួយគ្រូបច្ចុប្បន្នរបស់ពួកគេ មិនថាពួកគេត្រូវរៀនក្នុងកម្មវិធីសិក្សាបញ្ចូលគ្នា ឬ ក៏នៅតែរៀនតាមកុំព្យូទ័រ ១០០% នោះទេ។ យើងបានចំណាយប្រាក់ ៦ លានដុល្លារ ទៅលើបច្ចេកវិទ្យាថ្មី ដើម្បីឱ្យគ្រូអាចបង្រៀនតាមកុំព្យូទ័រដោយផ្ទាល់ពីថ្នាក់រៀនរបស់ពួកគាត់ បង្រៀនសិស្សដែលទៅរៀននៅសាលាដោយផ្ទាល់ និង សិស្សចុចចូលរៀបពីផ្ទះ ក្នុងពេលតែមួយ។ ទោះជាយ៉ាង

ណាក៏ដោយ បើសិនជាមានគ្រូជាច្រើនមិនអាចបង្រៀននៅសាលាដោយផ្ទាល់បាន ដោយសារបញ្ហាសុខភាព ឬ បញ្ហាផ្សេងៗទៀត សិស្សជាច្រើនប្រហែលជាមិនអាចនៅរៀនជាមួយគ្រូរបស់ពួកគេបច្ចុប្បន្ននេះបានទេ។ ក្នុងករណីទាំងនោះ គេនឹងចាត់គ្រូផ្សេងឱ្យបង្រៀនវិញ។

### តើដំណើរការនៃការជ្រើសរើសនឹងធ្វើឡើងយ៉ាងដូចម្តេច?

មានតែក្រុមគ្រួសាររបស់សិស្សថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី ២ តែប៉ុណ្ណោះដែលត្រូវធ្វើការជ្រើសរើសក្នុងអំឡុងពេលនៃការជ្រើសរើសពីថ្ងៃទី ២៦ ដល់ថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០២០ ។ បើសិនជាគ្មានការជ្រើសរើសនៅថ្ងៃផុតកំណត់ទេ កូនរបស់លោកអ្នកនឹងនៅតែបន្តរៀនតាមកុំព្យូទ័រ ១០០%។ យើងនឹងចែកជូនព័ត៌មានលម្អិតក្នុងពេលឆាប់ៗនេះ។

### តើមានអ្វីកើតឡើងបើសិនជាខ្ញុំជ្រើសរើសការសិក្សាបញ្ចូលគ្នា ហើយកូនរបស់ខ្ញុំត្រូវការដាក់ឱ្យនៅដាច់ពីគេជាបណ្តោះអាសន្ន ឬ ថ្នាក់រៀន/ សាលារៀន ត្រូវបិទជាបណ្តោះអាសន្ន?

សិស្សដែលរងផលប៉ះពាល់នឹងប្តូរទៅរៀនតាមកុំព្យូទ័រពីផ្ទះវិញ រហូតទាល់តែមានសុវត្ថិភាពក្នុងការបន្តកាលវិភាគនៃការទៅរៀននៅសាលាដោយផ្ទាល់របស់ពួកគេ។

### បើសិនជាខ្ញុំជ្រើសរើសកម្មវិធីសិក្សាបញ្ចូលគ្នា តើខ្ញុំនឹងទទួលម្ហូបអាហារនៅថ្ងៃដែលខ្ញុំរៀនតាមកុំព្យូទ័រយ៉ាងដូចម្តេច?

សិស្សានុសិស្សនឹងទទួលម្ហូបអាហារសម្រាប់ថ្ងៃរៀនតាមកុំព្យូទ័រពេញលេញរបស់ពួកគេ នៅថ្ងៃចុងក្រោយនៃការទៅរៀននៅសាលាផ្ទាល់របស់ពួកគេ ជារៀងរាល់សប្តាហ៍។

*ឧទាហរណ៍៖ សិស្សក្រុម A ទៅរៀនដោយផ្ទាល់ នៅថ្ងៃច័ន្ទ និង ថ្ងៃអង្គារ នឹងយកម្ហូបអាហារសម្រាប់ថ្ងៃពុធ ដល់ថ្ងៃសុក្រ ពីសាលានៅថ្ងៃអង្គារ។*

### **តើខ្ញុំអាចស្វែងយល់បន្ថែមដោយវិធីណា មុនពេលខ្ញុំធ្វើការជ្រើសរើស?**

ចូលមើលវិបសៃ៖ philasd.org/AES.